ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

# ផែនការយុទ្ធសាស្ត្រ

## ឆ្នាំ២០១៤-២០១៨

ខែ ឧសភា ឆ្នាំ ២០១៤

# សេចក្តីផ្តើម ( Introduction )

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (វ.ប.ក) គឺជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈដែលបានចាប់ដំណើរការបណ្តុះបណ្តាលថ្នាក់អ្នកបច្ចេកទេសជាន់ខ្ពស់និងថ្នាក់វិស្វករតាំងពីឆ្នាំ១៩៦៤ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិកម្ពុជា។ បច្ចុប្បន្ន វ.ប.ក ត្រូវបានគេទទួលស្គាល់ទាំងក្នុងតំបន់និងអន្តរជាតិតាមរយៈកិច្ចសហប្រតិបត្តិការយ៉ាងទូលំទូលាយរួមនឹងកិច្ចព្រមព្រៀងជាច្រើនទៀតជាមួយសាកលវិទ្យាល័យនៅសហគមន៍អឺរ៉ុប សាកលវិទ្យាល័យនិយាយភាសាបារាំង ជប៉ុន កូរ៉េ និងនៅក្នុងតំបន់ដែលជាមូលដ្ឋាននៃការពង្រឹងនូវសមត្ថភាពបណ្តុះបណ្តាល។ បន្ថែមពីលើនេះទៀតវិទ្យាស្ថានក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយរោងចក្រសហគ្រាស ក្រុមហ៊ុនជាតិនិងអន្តរជាតិជាច្រើនដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជា ដោយពង្រឹងនូវចំណេះដឹងក៏ដូចជាចំណេះធ្វើដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។

ឆ្លងតាមបទពិសោធន៍ដែលបានអនុវត្តកន្លងមកនេះ យើងអាចវាយតម្លៃបានថា វិទ្យាស្ថានកំពុងស្ថិតនៅក្នុងគោលដៅពិតប្រាកដរបស់ខ្លួនគឺផ្តល់នូវការអប់រំប្រកបដោយគុណភាពខ្ពស់ក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ព្រមទាំងអភិវឌ្ឍការងារស្រាវជ្រាវវិទ្យាសាស្ត្រ និងផ្ទេរបច្ចេកវិទ្យាឲ្យសមស្របទៅតាមតម្រូវការវិវឌ្ឍន៍របស់សង្គម និងសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ម្យ៉ាងវិញទៀតចំពោះកិច្ចការរដ្ឋបាលដូចជារបៀបគ្រប់គ្រងការងារ និងរចនាសម្ព័ន្ធនៃថ្នាក់ដឹកនាំនានា ចាំបាច់ត្រូវតែកែសម្រួលឲ្យកាន់តែប្រសើរឡើងស្របទៅនឹងការរីកចំរើនរបស់វិទ្យាស្ថានដែលជាគ្រឹះស្ថានឧត្តមសិក្សាបច្ចេកទេសឈានមុខនៅក្នុងប្រទេស ក្នុងការបណ្តុះបណ្តាលធនធានមនុស្សខាងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

វិទ្យាស្ថានបានធ្វើការបណ្តុះបណ្តាលតាមកម្មវិធីសិក្សាថ្នាក់ជាតិសម្រាប់កម្រិតមធ្យមសិក្សាបច្ចេកទេស ថ្នាក់វិស្វករនិងថ្នាក់ក្រោយបរិញ្ញាបត្រស្របតាមផែនការយុទ្ធសាស្ត្ររបស់វិទ្យាស្ថាន។ តាមរយៈនៃការអនុវត្តផែនការយុទ្ធសាស្ត្រកន្លងមក វិទ្យាស្ថានទទួលបាននូវសមិទ្ធផលសំខាន់ៗជាច្រើនដូចជា៖

- មានការទទួលស្គាល់និងការលើកសរសើរពីក្រសួងអប់រំយុវជននិងកីឡា លើការគ្រប់គ្រងវិទ្យាស្ថាន និងបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាព
- មានការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិសម្រាប់ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានបីលើកជាប់គ្នា ពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- មានការគាំទ្រជាច្រើនពីសំណាក់ក្រសួងមន្ទីរ ក្រុមហ៊ុន សហគ្រាស និងពីដៃគូអភិវឌ្ឍន៍
- បានសង់អគារមួយខ្នងកម្ពស់៤ជាន់ និងសាលសហសិក្សាមួយខ្នងដោយថវិការបស់រាជរដ្ឋាភិបាល
- កំពុងសាងសង់មជ្ឈមណ្ឌលស្រាវជ្រាវ១ខ្នងដោយប្រើថវិកាជំនួយរបស់រាជរដ្ឋាភិបាលជប៉ុន
- មានការទទួលស្គាល់គុណភាពបណ្តុះបណ្តាលនិងងាយស្រួលក្នុងការធ្វើសមាហរណកម្មធនធានមនុស្សទៅក្នុងទីផ្សារការងារ។ ជាក់ស្តែងនិស្សិតដែលបានបញ្ចប់ការសិក្សាពីវិទ្យាស្ថានស្ទើរតែទាំងអស់ទទួលបានការងារធ្វើក្នុងពេលកំពុងសិក្សា និងពេលបញ្ចប់ការសិក្សា

- មានការទទួលស្គាល់គាំទ្រពីដៃគូជាតិនិងអន្តរជាតិ និងឈានទៅដល់ការចុះអនុស្សរណៈយោគយល់ស្នើមុខឡាដើម្បីចូលរួមចំណែកកសាងធនធានមនុស្សបង្កើតមន្ទីរពិសោធន៍ ពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងបណ្ណាល័យ។ល។
- បានពង្រឹងសមត្ថភាពសាស្ត្រាចារ្យតាមរយៈនៃការបញ្ជូនទៅចូលរួមធ្វើសិក្ខាសាលា វគ្គបណ្តុះបណ្តាលរយៈពេលវែងនិងខ្លី ទាំងក្នុងប្រទេស និងក្រៅប្រទេស
- បានអភិវឌ្ឍកម្មវិធីសិក្សាស្របតាមតម្រូវការទីផ្សារការងារ ដោយមានកិច្ចសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិ និងដៃគូឯកជន
- បានផ្លាស់ប្តូរបទពិសោធន៍នានា តាមរយៈទស្សនកិច្ចសិក្សាផ្លាស់ប្តូរនិស្សិតជាមួយគ្រឹះស្ថានបណ្តុះបណ្តាលល្បីៗទាំងក្នុងនិងក្រៅប្រទេស
- បានលើកទឹកចិត្តនិស្សិតពូកែៗដោយផ្តល់អាហារូបករណ៍ទៅសិក្សាបន្តនៅក្រៅប្រទេស តាមរយៈដៃគូអភិវឌ្ឍន៍
- សមត្ថភាពស្រាវជ្រាវវិទ្យាសាស្ត្រត្រូវបានពង្រឹង តាមរយៈកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យជាដៃគូ ស្ថាប័នរដ្ឋ និងឯកជន
- បានបង្កើតមុខជំនាញថ្មី និងកំពុងដាក់ឲ្យដំណើរការដេប៉ាតឺម៉ង់ធនធានរ៉ែ និងភូគព្ភសាស្ត្រ
- បានបង្កើត និងកំពុងដំណើរការថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើជំនាញវិស្វកម្មសំណង់ស៊ីវិល វិស្វកម្មអគ្គិសនីនិងថាមពល វិស្វកម្មគ្រប់គ្រងធនធានទឹក វិស្វកម្មគីមីនិងអាហារ វិស្វកម្មឧស្សាហកម្មនិងមេកានិច និងព័ត៌មានវិទ្យា។

ទន្ទឹមនឹងភាពជោគជ័យក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រដែលសម្រេចបាននូវសមិទ្ធផលសំខាន់ៗខាងលើនេះ វិទ្យាស្ថានកំពុងតែជួបនឹងបញ្ហាប្រឈមមួយចំនួនដូចតទៅ៖

១-ធនធានសម្ភាររូបវ័ន្តសម្ភារគាំទ្រឲ្យការបង្រៀន ការស្រាវជ្រាវ ធនធានសាស្ត្រាចារ្យ និងកម្មវិធីសិក្សាតម្រូវឲ្យវិទ្យាស្ថានត្រូវតែអភិវឌ្ឍជាបន្ថែមទៀត

២-ការផ្លាស់ប្តូរបទពិសោធន៍លើការងារបង្រៀន ការងារសិក្សានិងការងារស្រាវជ្រាវ ការផ្លាស់ប្តូរវប្បធម៌ដឹកនាំការងារ ការផ្លាស់ប្តូរនិស្សិត ទស្សនកិច្ចសិក្សា ការងារស្រាវជ្រាវវិទ្យាសាស្ត្រការផ្តល់អាហារូបករណ៍សម្រាប់និស្សិតសាស្ត្រាចារ្យ និងបុគ្គលិកតម្រូវឲ្យមានសកម្មភាពបន្ថែមទៀត

៣-ការស្រាវជ្រាវសម្រាប់កិច្ចការបង្រៀនរបស់គ្រូម្នាក់ៗតម្រូវឲ្យមានការអភិវឌ្ឍបន្ថែមទៀត

៤-ការស្រាវជ្រាវវិទ្យាសាស្ត្រតម្រូវឲ្យមានការអភិវឌ្ឍសមត្ថភាពដល់អ្នកស្រាវជ្រាវបន្ថែម

៥-ការគ្រប់គ្រងនិងការដឹកនាំរបស់វិទ្យាស្ថាននៅមានជួបនឹងបញ្ហាប្រឈមដូចជា ការទប់បុគ្គលិកល្អៗកុំឲ្យផ្លាស់ចេញ ការមិនបានផ្តល់តួនាទី និងឋានៈផ្សេងៗ និងស្ថានភាពហិរញ្ញវត្ថុនៅមានកម្រិតនៅឡើយ ។

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាបានរៀបចំផែនការយុទ្ធសាស្ត្រថ្មី សម្រាប់រយៈពេល៥ឆ្នាំខាងមុខ (២០១៤-២០១៨) ដោយផ្អែកទៅលើលទ្ធផលនៃការវាយតម្លៃយ៉ាងល្អិតល្អន់នូវលទ្ធផលដែលបានអនុវត្តផែនការយុទ្ធសាស្ត្រកន្លងមក ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ផែនការយុទ្ធសាស្ត្រនេះ គឺជាមាគ៌ាសម្រាប់តម្រង់ទិសក្នុងការអនុវត្តន៍សកម្មភាពការងារនៅក្នុងវិទ្យាស្ថានប្រកបដោយប្រសិទ្ធភាពខ្ពស់ សំដៅដោះស្រាយបញ្ហាប្រឈមទាំងឡាយ ដើម្បីលើកកម្ពស់គុណភាពបណ្តុះបណ្តាលផ្នែកវិស្វកម្មឲ្យកាន់តែប្រសើរក្នុងលក្ខណៈប្រកួតប្រជែងខ្ពស់ និងសម្រាប់ការចូលរួមលើកកម្ពស់កម្រិតជីវភាពប្រជាជនឲ្យបានប្រសើរឡើង ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ប្តេជ្ញាអនុវត្តផែនការយុទ្ធសាស្ត្រថ្មីនេះឲ្យបានជោគជ័យតាមការរំពឹងទុកតាមរយៈនៃការដាក់ចេញនូវគោលបំណង គោលដៅយុទ្ធសាស្ត្រ និងគោលនយោបាយសំខាន់ៗមួយចំនួនទៀតដូចមានចែងលម្អិតក្នុងផែនការយុទ្ធសាស្ត្រថ្មីនេះ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤

នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

បណ្ឌិត អ៊ុម រម្យណី

- ជម្រុញឲ្យមានការចែករំលែក និងផ្លាស់ប្តូរបទពិសោធន៍នៃការរៀន
- បន្តពង្រឹងដំណើរការនៃការវាយតម្លៃគុណភាពនៃការរៀន
- បន្តតាមដានប្រសិទ្ធភាពនៃការរៀនរបស់និស្សិត
- បង្កើនចំនួនអាហារូបករណ៍ដល់និស្សិតពូកែ និងនិស្សិតក្រីក្រ
- ពង្រឹងការចុះធ្វើកម្មសិក្សា និងទស្សនកិច្ចសិក្សារបស់និស្សិត
- បន្តជម្រុញសកម្មភាពកីឡា និងសិល្បៈឲ្យកាន់តែផុលផុស
- បន្តបំផុសនិស្សិតឲ្យរក្សាបាននូវសុខភាពល្អ និងអនាម័យ
- បន្តបំផុសនិស្សិតឲ្យចូលរួមក្នុងកិច្ចការសង្គម។

## គោលបំណងទី២

## ពង្រឹង និងពង្រីកការស្រាវជ្រាវវិទ្យាសាស្ត្រ ផ្ទេរបច្ចេកវិទ្យា និងកិច្ចសហប្រតិបត្តិការ

រាជរដ្ឋាភិបាលបានលើកកម្ពស់និងគាំទ្រដល់ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ ការច្នៃប្រឌិត និងការផលិតដែលមានលក្ខណៈវិទ្យាសាស្ត្រ ជាការឆ្លើយតបទៅនឹងទីផ្សារពលកម្មនិងស្របតាមសាកលភាវូបនីយកម្មដើម្បីលើកស្ទួយសមត្ថភាពធនធានមនុស្ស និងជំរុញការអភិវឌ្ឍប្រទេសជាតិ។ក្រសួងអប់រំ យុវជននិងកីឡាបានកំណត់គោលការណ៍ស្តីពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់គ្រប់ភូមិសិក្សាស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ដើម្បីរួមចំណែកអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាការកំណត់គោលការណ៍ស្តីពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់គ្រប់ភូមិសិក្សា វិទ្យាស្ថានបានដាក់ចេញជាគោលធំៗក្នុងបំណងដើម្បីពង្រឹងនិងពង្រីកការស្រាវជ្រាវវិទ្យាសាស្ត្រផ្ទេរបច្ចេកវិទ្យានិងកិច្ចសហប្រតិបត្តិការ ក្នុងផែនការយុទ្ធសាស្ត្ររបស់វិទ្យាស្ថានសម្រាប់ឆ្នាំសិក្សា២០១៤ ដល់២០១៨។ គោលបំណងទី២នេះគឺបង្កើតឡើងដើម្បីសម្រេចនូវបេសកកម្មដែលមានគោលដៅចំនួន៥ដូចខាងក្រោម៖

**១-លើកកម្ពស់សមត្ថភាពវិទ្យាសាស្ត្រ**

**២-បន្តកសាងអ្នកស្រាវជ្រាវវិទ្យាសាស្ត្រប្រកបដោយសមត្ថភាពខ្ពស់**

**៣-លើកកម្ពស់សមត្ថភាពមន្ទីរពិសោធន៍**

**៤-ពង្រឹង និងពង្រីកបណ្តាញអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ**

**៥-ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយសហគ្រាសឯកជន**

## ១.លើកកម្ពស់សមត្ថភាពវិទ្យាសាស្ត្រ

គោលដៅនេះបង្កើតឡើងដើម្បីសម្រេចឲ្យបានគោលបំណងទី២ដែលមានយុទ្ធសាស្ត្រដូចខាងក្រោម៖

- លើកទឹកចិត្តឲ្យអ្នកស្រាវជ្រាវចូលរួមធ្វើគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រជាមួយដៃគូជាតិ និងអន្តរជាតិ
- ផ្លាស់ប្តូរបទពិសោធន៍ជាមួយអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិតាមរយៈការចូលរួមសន្និសីទវិទ្យាសាស្ត្រ សិក្ខាសាលា។ល។

## ២. បណ្តុះបណ្តាលអ្នកស្រាវជ្រាវវិទ្យាសាស្ត្រប្រកបដោយសមត្ថភាពខ្ពស់

ដើម្បីសម្រេចបាននូវគោលបំណងទី២ វិទ្យាស្ថានបានដាក់ចេញគោលដៅយុទ្ធសាស្ត្រដូចខាងក្រោម៖

- លើកទឹកចិត្តអ្នកស្រាវជ្រាវដែលមានសញ្ញាបត្រអនុបណ្ឌិត ឬបណ្ឌិតឲ្យបន្តសិក្សាថ្នាក់បណ្ឌិត ឬថ្នាក់ក្រោយបណ្ឌិត (Post-doctoralprogram)
- បញ្ជូនអ្នកស្រាវជ្រាវឲ្យទៅផ្លាស់ប្តូរបទពិសោធន៍នៅតាមមន្ទីរពិសោធន៍នៃដៃគូវិទ្យាស្ថាន
- អភិវឌ្ឍសមត្ថភាពជំនាញសរសេរគម្រោងស្រាវជ្រាវ និងស្នើមូលនិធិ (Project proposal)
- អភិវឌ្ឍសមត្ថភាពជំនាញ រៀបចំផែនការស្រាវជ្រាវ គ្រប់គ្រងគម្រោង និងសរសេររបាយការណ៍ស្រាវជ្រាវ។

## ៣. លើកកម្ពស់សមត្ថភាពមន្ទីរពិសោធន៍

យុទ្ធសាស្ត្រខាងក្រោមនេះជាគោលដៅគន្លឹះដើម្បីសម្រេចឲ្យបាននូវគោលបំណងទី២ រួមមាន៖

- បង្កើនចំនួនមន្ទីរពិសោធន៍តាមឯកទេសឲ្យឆ្លើយតបនឹងការវិវឌ្ឍន៍របស់វិទ្យាសាស្ត្រ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ
- ស្វះស្វែងរកការគាំទ្រពីរាជរដ្ឋាភិបាល និងរកថវិកាពីដៃគូអភិវឌ្ឍនានាដើម្បីបំពាក់គ្រឿងបរិក្ខារទំនើបបន្ថែមទៀតក្នុងបំណងបម្រើឲ្យការងារស្រាវជ្រាវវិទ្យាសាស្ត្រ
- បន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយភាគី បារាំង បែលហ្ស៊ិក ជប៉ុន កូរ៉េ និងរដ្ឋាភិបាលនៃប្រទេសក្នុងអាស៊ាន ក្នុងបំណងលើកកម្ពស់សមត្ថភាពបេសកម្មរបស់វិទ្យាស្ថាន។

## ៤.ពង្រឹង និងពង្រីកបណ្តាញអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ

គោលដៅគន្លឹះជាបន្ទាប់គឺ៖

- បន្តលើកគម្រោងស្រាវជ្រាវវិទ្យាសាស្ត្រជាមួយដៃគូជាតិ និងអន្តរជាតិ និងភាគីឯកជន
- ចូលរួមសន្និសីទវិទ្យាសាស្ត្រនានាដើម្បីផ្លាស់ប្តូរ និងចែករំលែកបទពិសោធន៍
- អញ្ជើញអ្នកស្រាវជ្រាវវិទ្យាសាស្ត្រជាតិ និងអន្តរជាតិឲ្យចូលរួមក្នុងសិក្ខាសាលាឬសន្និសីទវិទ្យាសាស្ត្រដែលរៀបចំដោយវិទ្យាស្ថាន
- លើកគម្រោងស្រាវជ្រាវរួមគ្នាជាមួយដៃគូជាតិនិងអន្តរជាតិផ្សេងទៀត (Join project programs)

- អញ្ជើញអ្នកស្រាវជ្រាវវិទ្យាសាស្ត្រផ្សេងទៀតឲ្យចូលរួមក្នុងសិក្ខាសាលា ឬសន្និសីទវិទ្យាសាស្ត្រដែលរៀបចំដោយវិទ្យាស្ថាន។

**៥.ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយសហគ្រាសឯកជន**

គោលដៅនេះមានយុទ្ធសាស្ត្រដូចតទៅ៖

- ផ្តល់ឱកាសឲ្យសហគ្រាសទាំងឡាយបានស្វែងយល់អំពីបេសកម្មរបស់វិទ្យាស្ថាន
- ស្តាប់នូវប្រតិកម្មរបស់សហគ្រាសអំពីគុណភាពបណ្តុះបណ្តាល
- ទាញសហគ្រាសឯកជនឲ្យខិតចូលមកជិតគ្រឹះស្ថានសិក្សាក្នុងបំណងបង្កភាពស្និតស្នាល
- ផ្តល់ឱកាសឲ្យសហគ្រាសនានាបង្កើត Liaison office ជាមួយវិទ្យាស្ថានដើម្បីបង្កឱកាសការងារដល់និស្សិតដែលបានបញ្ចប់ការសិក្សាថ្មីៗ
- បន្តរៀបចំសន្និសីទវិទ្យាសាស្ត្រ ដើម្បីចែករំលែកបទពិសោធន៍ ដែលមានការចូលរួមពីសាកលវិទ្យាល័យ និងសហគ្រាសឯកជន
- បន្តផ្តល់សេវាដល់សហគ្រាសឯកជនដូចជាផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេស ផ្តល់ការវិភាគវត្ថុធាតុដើមនិងផលិតផលសម្រេច ផ្តល់ការប្រឹក្សាបច្ចេកទេស។ល។
- បើកគម្រោងស្រាវជ្រាវដើម្បីអភិវឌ្ឍបច្ចេកទេសផលិតកម្មជាមួយសហគ្រាសឯកជនដទៃទៀត
- សហការធ្វើសន្និសីទវិទ្យាសាស្ត្រដើម្បីចែករំលែកបទពិសោធន៍ ដោយមានការចូលរួមពីសាកលវិទ្យាល័យនានា និងសហគ្រាសឯកជនដទៃទៀត។

## គោលបំណងទី៣

## អភិបាលកិច្ចល្អ

អភិបាលកិច្ចល្អគឺជាលក្ខណៈវិនិច្ឆ័យសំខាន់បំផុតមួយ ដើម្បីធានាឱ្យមាននូវការអភិវឌ្ឍប្រកបដោយចីរភាព មានសមធម៌ និងយុត្តិធម៌ក្នុងអង្គភាព។ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បាននិងកំពុងអនុវត្តអភិបាលកិច្ចល្អគឺតម្រូវឱ្យមានគណនេយ្យភាព តម្លាភាព លក្ខណៈស្មើភាពហើយនឹងមានការប្រតិបត្តិតាមវិធានច្បាប់មានការបើកចំហសំការចែករំលែកពត៌មាននិងមានការចូលរួមយ៉ាងទូលំទូលាយ។ គោលបំណងទី៣នេះបង្កើតឡើងដើម្បីសម្រេចបេសកកម្មដែលមានគោលដៅចំនួន៣ដូចខាងក្រោមគឺ ៖

**១.ពង្រឹងគណនេយ្យភាពនៅក្នុងអង្គភាព**

**២.ពង្រឹងតម្លាភាពក្នុងអង្គភាពឲ្យកាន់តែប្រសើរឡើង**

**៣.ពង្រឹងនិងពង្រីកការចូលរួមពីសាស្ត្រាចារ្យបុគ្គលិក និងនិស្សិត**